**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ៣៦៩/៩៥៨ សរ.កសក.ផផក

# សារាចរណែនាំ

## ស្តីពី

## ការពង្រឹងសមត្ថភាពអង្គភាពទទួលបន្ទុកការងារ ស្ថិតិ និង គោលនយោបាយ ផែនការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

វិស័យកសិកម្ម មានតួនាទីសំខាន់សំរាប់បំរើជីវភាពរបស់ប្រជាពលរដ្ឋ និង សេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាជាយូរលង់មកហើយ ហើយនឹងនៅតែមានតួនាទីសំខាន់ជាយូរអង្វែងតទៅមុខទៀត ថ្វីត្បិតតែក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះមានការរីកចំរើនមួយគឺរតនៃផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម និង សេវាកម្មក្តី ។ ក៏ប៉ុន្តែស្ថានភាពអសន្តិសុខស្បៀង និង ភាពក្រីក្រ នៅមានអត្រាខ្ពស់នៅក្នុងចំណោមប្រជាពលរដ្ឋជាពិសេសកសិករសុទ្ធសាធដែលរស់នៅជនបទ ។ សភាពការណ៍នេះបណ្តាលមកពីផលិតកម្មកសិកម្មមានលក្ខណៈមិនទៀងទាត់ដោយនៅពឹងផ្អែកលើកត្តាធម្មជាតិច្រើន ទម្រង់ផលិតកម្មមិនទាន់សម ស្របបច្ចេកវិជ្ជាផលិតកម្មនៅមានកំរិតដោយខ្សែផ្នែកកសិ-ឧស្សាហកម្មនិងកសិ-ពាណិជ្ជកម្មមិនទាន់រីកចំរើនដែលធ្វើអោយកសិករបាត់បង់ឱកាសទទួលបាននូវតម្លៃបន្ថែម និងកំរៃសមស្របពី ផលិតផលរបស់ខ្លួនដើម្បីរំដោះខ្លួនចេញពីភាពក្រីក្របាន ។

ក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរី កត្តាជោគជ័យ និង រីកចំរើននៃផលិតកម្មកសិកម្ម ក្រៅពីមានបច្ចេកវិជ្ជាខ្ពស់ មធ្យោបាយផលិតកម្ម និងហេដ្ឋារចនាសម្ព័ន្ធជារូបវន្តជឿនលឿននោះ គឺការមានគោលនយោបាយ ផែនការ និង យុទ្ធសាស្ត្រ មួយដ៏ត្រឹមត្រូវប្រកបដោយភាពឈ្លាសវៃក្នុងការសំរេចចិត្តជាយុទ្ធសាស្ត្រ និង ដាក់ចេញនូវគោលនយោបាយ និង ផែនការ សកម្មភាព ក្រោយពីបានវិភាគគ្រប់ជ្រុងជ្រោយទាំងកត្តាខាងក្នុង និងកត្តាខាងក្រៅដោយផ្អែកលើទិន្នន័យព័ត៌មានស្ថិតិមួយមានភាពត្រឹមត្រូវច្បាស់លាស់ និង តាមពេលវេលាមួយទៀងទាត់ ។

ការងារស្ថិតិ ការងារគោលនយោបាយ ផែនការ ជាមធ្យោបាយចំបងសំរាប់ថ្នាក់ដឹកនាំនយោបាយធ្វើការសំរេចចិត្ត ។ អង្គភាពទទួលបន្ទុកវិភាគគោលនយោបាយផែនការ ជាធម្មតាជាសេនាធិការផ្ទាល់ និង ជាប្រចាំនៅជាប់ជាមួយថ្នាក់ដឹកនាំ ស្ថាប័ន ឬ អង្គភាព ។

ការសិក្សា ការអង្កេតវាយតំលៃដោយជំនាញការនៃទីភ្នាក់ងារអភិវឌ្ឍន៍កសិកម្ម សហគមន៍អ្នកផ្តល់ជំនួយនានា កន្លងមកជាច្រើនបានលើកឡើងអំពីភាពទន់ខ្សោយ ឬ ខ្វះខាតនូវផ្នែកយុទ្ធសាស្ត្រ និង គោលនយោបាយផែនការមួយសមស្រប នៃវិស័យកសិកម្ម ក៏ដូចជាភាពខ្វះខាតនូវទិន្នន័យព័ត៌មានស្ថិតិសេដ្ឋកិច្ចនានា ។

<u>ស្មារតីសន្និបាតបូកសរុបលទ្ធផលការងារ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០០២-២០០៣ និង លើកទិសដៅ ឆ្នាំ</u> ២០០៣-២០០៤ ជាពិសេសអនុសាសន៍របស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាក្នុងឱកាសពិធីបិទសន្និបាតខាងលើនេះបានលើកឡើងច្បាស់លាស់ថា "ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចាត់វិធានការដើម្បីរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយអោយបានច្បាស់លាស់ដើម្បី រាជរដ្ឋាភិបាលអាចដោះស្រាយបញ្ហាប្រឈមមុខរបស់កម្ពុជា ក្នុងអណត្តិខាងមុខ" និង "ទាមទារអោយមានកិច្ច សហការគ្នាយ៉ាងជិតស្និទ្ធ រវាងក្រសួងពាក់ព័ន្ធ អង្គការអន្តរជាតិ អង្គការមិន មែនរដ្ឋាភិបាល ប្រទេសម្ចាស់ជំនួយ និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព នូវថវិការដ្ឋ ក្នុងការអនុវត្តន៍ កម្មវិធីដែលបានដាក់ចេញ" ។ ដូច្នេះចាំបាច់ត្រូវពង្រឹងសមត្ថភាព និងការរៀបចំគោលនយោបាយយុទ្ធសាស្ត្រ កសិកម្ម អោយសមស្របទើបវិស័យនេះមានការរីកចំរើនបានឆាប់រហ័ស និង ប្រកបដោយនិរន្តរភាព ។

ផ្អែកលើសភាពការណ៍រួមទាំងអស់ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានទិសដៅចំពោះមុខ ពង្រឹងអង្គភាព និងផ្នែកទទួលបន្ទុក ស្ថិតិ និងគោលនយោបាយ ផែនការអភិវឌ្ឍន៍កសិកម្មអោយមានសមត្ថភាពសមស្រប នៅថ្នាក់កណ្តាល ខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ ។

ដើម្បីរួមគ្នាសំរេចបានតាមទិសដៅនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សូមធ្វើការណែនាំដល់អង្គភាព ក្រោមឱវាទថ្នាក់កណ្តាល និង ខេត្ត-ក្រុង ទាំងអស់ ដើម្បីយកចិត្តទុកដាក់មានវិធានការដូចតទៅ ÷

១- គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវយកចិត្តទុកដាក់ពង្រឹងការិយាល័យ ឬ ផ្នែកផែនការ ស្ថិតិនៃអង្គភាពឡើងវិញអោយមានសមត្ថភាពខ្ពស់អាចជួយប្រធានអង្គភាពក្នុងការប្រមូលព័ត៌មាន និង ទិន្នន័យស្ថិតិគ្រប់បែបយ៉ាងបានរហ័សទាន់ពេល មានភាពត្រឹមត្រូវ និង ចេះកែច្នៃ វិភាគបានប្រសើរ ។

២- ផ្អែកលើទិន្នន័យ និង លទ្ធផលនៃការវិភាគនេះត្រូវចេះរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ តាមជំនាញ និង តាមមូលដ្ឋាន ខេត្ត-ក្រុង ប្រកបដោយប្រសិទ្ធិភាពខ្ពស់ស្របតាមគោល នយោបាយ យុទ្ធសាស្ត្រ និង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់រាជរដ្ឋាភិបាល និង ស្ថានភាពធនធានជាក់ ស្តែងនៃ ជំនាញ និង មូលដ្ឋាននីមួយៗ ។

៣- ត្រូវយកចិត្តទុកដាក់ធ្វើអោយប្រសើរឡើងនូវរបៀបរបបការងារដោយត្រូវផ្អែកលើយុទ្ធសាស្ត្រគោល នយោបាយ ផែនការ និង កម្មវិធី សកម្មភាពមួយច្បាស់លាស់តាមដំណាក់កាលនីមួយៗ ។

៤- ត្រូវយកចិត្តទុកដាក់រៀបចំអោយមានធនធានមនុស្សប្រកបដោយសមត្ថភាពខ្ពស់ ពិសេសត្រូវយកចិត្តទុកដាក់ ចំពោះមន្ត្រីវ័យក្មេងមានជំនាញ ឬ ចំណេះដឹងមូលដ្ឋានខាងសេដ្ឋកិច្ច ដើម្បីទទួលស្រូបយកនូវ ការបណ្តុះបណ្តាល ផ្នែកជំនាញគោលនយោបាយផែនការ ស្ថិតិ ពីគំរោងនានា ក្នុងពេលខាងមុខបន្ត បន្ទាប់ ។

៥- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្ត-ក្រុង ត្រូវមានវិធានការជាបន្ទាន់រៀបចំអោយមានជាផ្នែក ស្ថិតិកសិកម្ម នៅក្នុងការិយាល័យកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ថ្នាក់ស្រុក ខ័ណ្ឌ ដែលអាចមានមន្ត្រីទទួលបន្ទុកពី ១ ទៅ ៣ នាក់ ដោយជ្រើសរើសនូវមន្ត្រីដែលមាននៅនឹងទីកន្លែង ស្រាប់ធ្លាប់ទទួលការបណ្តុះបណ្តាលរួចហើយ ឬ មន្ត្រីវ័យក្មេង ដែលមានលក្ខណៈអាចទទួលនូវការ បំពាក់បំប៉នជំនាញបានល្អ ។

៦- បង្កលក្ខណៈលើកទឹកចិត្តដល់មន្ត្រីនៃអង្គភាពស្ថិតិ និង គោលនយោបាយ ផែនការ អោយអាចបំពេញភារកិច្ចបានល្អ ។

៧-នាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស នាយកដ្ឋានផែនការ ស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចសហការជាមួយអង្គភាពពាក់ព័ន្ធ រកគ្រប់លទ្ធភាពបណ្តុះបណ្តាល និងបំពាក់បំប៉ន ជំនាញ ស្ថិតិ និង គោលនយោបាយ ផែនការ អោយដល់មន្ត្រីគ្រប់ការិយាល័យ ឬផ្នែកផែនការស្ថិតិ នៃអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្ត-ក្រុង ។ ម្យ៉ាងទៀត ដើម្បីអោយការងាររៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងគំរោង ផែនការនានាបានត្រឹមត្រូវសមស្រប និងទាន់ពេលវេលា ត្រូវសិក្សាលទ្ធភាពរៀបចំប្រព័ន្ធយន្តការមួយ ដែលអាចសហការទំនាក់ទំនងធ្វើការជាមួយគ្នាប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្ត-ក្រុង ត្រូវយកចិត្តទុកដាក់ខ្ពស់ និង មានវិធានការអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់។

ភ្នំពេញ. ថ្ងៃទី ២១ ខែ ០៧ ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

ចាន់ សារុន

<u>កន្លែងទទួល</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត-ក្រុង

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ